មាតិកា

I.-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៥-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦៤ ស្តីពី ការតែងតាំងសម្តេច នរោត្តម សិរីវុឌ្ឍ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអាណត្តិថ្មី ៤២២៦

០៥-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៦៥ ស្តីពី ការតែងតាំងឯកឧត្តម សឺន សូប៊ែរ្តិ៍ ជា ឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ៤២២៧

០៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៧៥ ស្តីពី ការតែងតាំងឯកឧត្តម ចំនួន ០២ រូប ជាជំនួយការអមព្រះរាជលេខាធិការដ្ឋាន ព្រះមហាក្សត្រ មានឋានៈស្មើ អគ្គនាយក ៤២២៨

០៨-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៧៦ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម យូរ សំអ៊ើល ពីជំនួយការសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធ្មារ ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី ក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ អគ្គនាយក ដោយបានទទួលមរណភាព ៤២២៩

០៨-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៧៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក លូ ហ្ស៊ីយូ (LU ZIYU) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា លូ យ៉ាវយូ (LU YAO YU) ៤២៣០

១២-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៣៩៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក គ្រីស្តូហ្វឺអាឡិន ភូលីអូ (CHRISTOPHER ALLEN PULEO) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតនៅ រដ្ឋ New Jersey សហរដ្ឋអាមេរិក ៤២៣១

២៥-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤១៨ ស្តីពី ការប្រោសព្រះរាជទាន ចំពោះឯកឧត្តម ម៉ា ស៊ុនហួត នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤២៣២

២៦-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤២៩ ស្តីពី ការប្រោសព្រះរាជទាន ចំពោះឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីទុន និង លោកវេជ្ជបណ្ឌិត លី ពេញស៊ុន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤២៣៣

២៦-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៣០ ស្តីពី ការប្រោសព្រះរាជទាន ចំពោះឧកញ៉ា ឆា គង់ និង លោក ZHANG YI នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ៤២៣៤

២៦-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៣២ ស្តីពី ការតែងតាំងលោក សុខ ជា ជាឧកញ៉ា ៤២៣៥

២៦-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៣៣ ស្តីពី ការផ្ទេរលោក ស្រេង ខ៊ីន ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៤២៣៦

២៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៣៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម.លោកជំទាវ អស់លោក និងលោកស្រី ចំនួន ៥៩ រូប ៤២៣៧

២៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៣៨ ស្តីពី ការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈ ចំពោះ សពឯកឧត្តម ប៊ិន សំអុល នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៤២៣៩

២៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៣៩ ស្តីពី ការប្រោសព្រះរាជទាន ចំពោះលោក អាល់ប៊ែតូ តាតារ៉ូ នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤២៤០

២៩-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៤២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះលោកជំទាវ និងអស់លោក ចំនួន ១៨ រូប ៤២៤១

២៩-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៤៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ២៤ រូប ៤២៤២

២៩-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៤៥ ស្តីពី ការតែងតាំងសមាជិក នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ចំនួន ០៣ រូប ៤២៤៣

២៩-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៤៦ ស្តីពី ការប្រោសព្រះរាជទាន ចំពោះឯកឧត្តម លី គ្យុងស៊ូ (H.E.LEE KYONG SOO) នូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤២៤៥

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

៣១-៥-២០១០ -អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៤២៤៦

៣១-៥-២០១០ -អនុក្រឹត្យលេខ ៥៨១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤២៤៨

៣១-៥-២០១០ -អនុក្រឹត្យលេខ ៥៨២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤២៤៩

៣១-៥-២០១០ -អនុក្រឹត្យលេខ ៥៨៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤២៥០

០១-៦-២០១០ -អនុក្រឹត្យលេខ ៥៨៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤២៥២

០១-៦-២០១០ -អនុក្រឹត្យលេខ ៥៨៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤២៥៣

០១-៦-២០១០ -អនុក្រឹត្យលេខ ៥៨៦ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៤២៥៤

០១-៦-២០១០ -អនុក្រឹត្យលេខ ៥៨៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤២៥៦
០១-៦-២០១០ -អនុក្រឹត្យលេខ ៥៨៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤២៥៧
០១-៦-២០១០ -អនុក្រឹត្យលេខ ៥៨៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤២៥៨
០១-៦-២០១០ -អនុក្រឹត្យលេខ ៥៩០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤២៦៣
០១-៦-២០១០ -អនុក្រឹត្យលេខ ៥៩១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤២៦៩
០១-៦-២០១០ -អនុក្រឹត្យលេខ ៥៩២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤២៧១
០១-៦-២០១០ -អនុក្រឹត្យលេខ ៥៩៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤២៧៣

២-សារាចរ

៣១-៥-២០១០ -សារាចរលេខ ០៣ សរ ស្តីពី ការដោះស្រាយសំណង់បណ្តោះ អាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និង ទីប្រជុំជន ៤២៧៨

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០៨-២-២០១០ -ប្រកាសលេខ ០៦៤ ប្រក.កសក ស្តីពី ការរៀបចំគ្រប់គ្រង និង អភិរក្សសត្វខ្សឹប និង ជីវចម្រុះ នៃប្រព័ន្ធអេកូឡូស៊ីរូម ក្នុងភូមិសាស្ត្រ ខេត្តកំពង់ធំ និង ខេត្តសៀមរាប ៤២៨៣
១០-៣-២០១០ -ប្រកាសលេខ ០៩៩ ប្រក.កសក ស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន នៃការអនុវត្តកសិកម្មល្អ ក្នុងការងារផលិតកម្មផ្លែឈើ និង បន្លែស្រស់ ៤២៨៦

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

២១-៥-២០១០ -ប្រកាសលេខ ១៨៦ ប្រក.កសដជ ស្តីពី ការកំណត់ទំហំ រថយន្តដឹកទំនិញ និង រ៉ឺម៉កដែលបានកែច្នៃទ្រុង ៤៣០៨

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១២៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេស តិ ឡូជីស្ទិក ៤៣១៧
៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១៣០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេ & ជី ដាប់ប៊ែលយូ ៤៣១៩
៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១៣១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សុវណ្ណ រស្មី ៤៣២១
៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១៣៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អូអិមអាយស៊ី (ខេមបូឌា) ៤៣២៣
៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១៤០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ម៉ាន់ សុទ្ធី ឡូជីស្ទិក ៤៣២៥

៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១៥០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តែច ចាន់ត្រា ឌីវេឡុបមេន** ៤៣២៧

៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១៥១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈុន សុខ អាន** ៤៣២៩

៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១៥២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផលិតកម្ម ភ្នំពេញ** ៤៣៣១

៣១-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣១៥៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខនធីស ឡាញ (ខេមបូឌា) អិលធីឌី** ៤៣៣២

០៣-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣១៦០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទើលដឺ ខេមបូ អ៊ីមផត អិចផត** ៤៣៣៤

០៣-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣១៦១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អូ អេ** ៤៣៣៦

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងសម្តេច **នរោត្តម សិរីវុឌ្ឍ** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអាណត្តិថ្មី ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះ ។

នរោត្តម សីហមុនី

៣រល.១០០៥.៣៦៩
បានប្រថាប់ព្រះរាជលញ្ឆករហើយ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ឧសភា ឆ្នាំ ២០១០
សម្តេចចៅហ្វាវាំង ... រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL
... សំអុល

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

ឯកឧត្តម សឺន សូប៉ែត្រ

ជា

ឧត្តមប្រឹក្សាផ្ទាល់
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១០

ពរ.ល. ១០០៥. ៣៦៥
បានប្រទានព្រះរាជលញ្ឆករហើយ

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ [illegible] រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០
[illegible] ធ្វើប្រតិភូ [illegible] ស្ត្រីគ្រងជ័យ [illegible]
ឧបនាយករដ្ឋមន្ត្រី [illegible] ព្រះបរមរាជវាំង
[illegible]
គង់ សំអុល

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង

១- ឯកឧត្តម **ជុំ រដ្ឋារិទ្ធ** ជាជំនួយការអមព្រះរាជលេខាធិការដ្ឋាន ព្រះមហាក្សត្រ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- លោកជំទាវ **នាង សុភិរុណ** ជាជំនួយការអមព្រះរាជលេខាធិការដ្ឋាន ព្រះមហាក្សត្រ មានឋានៈស្មើ **អគ្គនាយក** ។

៣រ៧.១០០៥.៣៧៩

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
[illegible] ១០.រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០
សម្តេចចៅហ្វាវាំង [illegible] អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី [illegible] រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

គង់ សំអុល

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ NS / KRT-34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៨០៤/១៦៥ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៣០៩/៣១៦ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៩
- បានទ្រង់យល់សំណើសម្តេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ។

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **យូរ សារិន** ពីជំនួយការសម្តេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្គារ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ អគ្គនាយក ដោយបានទទួលមរណភាព ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

នរោត្តម សីហមុនី

៣រល. ១០០៥. ៣៩០

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ៩៨/១០......រ.ចច
ភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១០
សម្តេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE MINISTÈRE DU PALAIS

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លូ ហ្ស៊ីយូ** (LU ZIYU) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៥៨ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **លូ យ៉ាវយូ** (LU YAO YU) ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល. ១០០៥. ៣៩៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១០

លេខៈ ៣៥៩ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១០
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

[illegible]

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៣៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គ្រីស្តូហ្វឺអាឡិន ភូលីអូ** (CHRISTOPHER ALLEN PULEO) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧០ នៅរដ្ឋ New Jersey សហរដ្ឋអាមេរិក ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត អោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០០៥.៤០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១០

លេខៈ ៣៦៥ ច.ល
[illegible]ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០៥១០/៤៦៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ម៉ា ស៊ុនហួត

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣/ល.១០០៥.៤២៤

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១០ លេខៈ ៤០៥ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០៥១០/៤២៩

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្តមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១- ឯកឧត្តមវេជ្ជបណ្ឌិត **មាន ឈីធុន**
២- លោកវេជ្ជបណ្ឌិត **លី ពេញស៊ុន**

នូវ

គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.១០០៥.៤៣៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០ លេខ: ៥០៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ចិនកេន

នស/រកត/០៥១០/៤៣០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-ឧកញ៉ា ឆា គង់

២-លោក **ZHANG YI**

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.១០០៥.៤៣៦

នរោត្តម សីហមុនី

លេខៈ ៤០៣ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១០
ប្រធានអង្គភាពលេខាធិការដ្ឋានរាជរដ្ឋាភិបាល

[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៣២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក សុខ ជា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០០៥.៤៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០

លេខ: ៣៩៦ ច.ល
[illegible] ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រប់គ្រងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរ **លោក ស្រេង ច័ន** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុងឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ៧.១០០៥.៤៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០

លេខ: ៥២០ ច.ល

ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយសសម្តេចព្រះមហាក្សត្រិយានីព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា ចំពោះ៖

១-	ឯកឧត្តម	អ៊ុំ ម៉ារ៉ា	២-	ឯកឧត្តម	ស ខាវី

ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ៖

១-	ឯកឧត្តម	ឡុង សុវណ្ណ	៣-	ឧត្តមសេនីយ៍ត្រី	យ៉ុន គា អត្តលេខ ០០៥៤៦០
២-	លោក	ខួយ ឃុនហ៊ា	៤-	ឯកឧត្តម	ម៉ែន ឈីម

គ-គ្រឿងឥស្សរិយយសសេនាជ័យសិទ្ធ ចំពោះ៖

១-	ឧត្តមសេនីយ៍ត្រី	ម៉ៅ ពៅ	អត្តលេខ ០៦១២
២-	ឧត្តមសេនីយ៍ត្រី	សោម បុប្ផារ័ត្ន	អត្តលេខ ០០០៨១៤

ឃ-គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ៖

១-	ឯកឧត្តម	ណែម ទ៉ា	១១-	លោក	ឈីច ប៊ុនហៃ
២-	ឯកឧត្តម	ភារៈ ឈាន	១២-	លោក	កែច បេងវឌ្ឍន៍
៣-	ឯកឧត្តម	សុខ ប៊ុនឈាង	១៣-	លោក	តូច វង្ស
៤-	លោកជំទាវ	ចឹក ហេង	១៤-	លោក	អ៊ុង ឧទ្ធី
៥-	ឯកឧត្តម	យ៉ែម ផល្លា	១៥-	លោក	ថោង សាគឿន
៦-	ឯកឧត្តម	សូរ ផុន	១៦-	លោក	អ៊ុង ឧទ្ធី
៧-	ឯកឧត្តម	នង ចន	១៧-	លោក	ឃាំង យៀត
៨-	ឯកឧត្តម	សុខ សាន្តតារ៉ា	១៨-	លោក	ឯ សារឿ
៩-	លោកជំទាវ	មុយ ចំនួនចន	១៩-	លោក	រស់ ហេង
១០-	លោក	ស សំអុល	២០-	លោក	ជុំ ពុយ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២១- លោក កែ សេងគីម
២២- លោក លី ធឿនឡុក
២៣- លោក លឹម សឿ
២៤- លោក សោ សាវុធ
២៥- លោក កែវ ស៊ីម
២៦- លោក គង់ វិបុល
២៧- លោក រស់ សំផល
២៨- លោក ពីង ត្រីដា
២៩- លោក ផាន់ សំអាន
៣០- លោក មាស រដ្ឋាវុឌ្ឍ
៣១- លោកស្រី ខូយ ប៊ុនថាន្នី
៣២- លោក សេង សារី
៣៣- លោក ហាន ឆន
៣៤- លោក ខូយ យុនចន្ទរ័ត្ន
៣៥- លោក មុយ ចាន់ពេញ
៣៦- លោក នួន សុវណ្ណ
៣៧- លោកស្រី ទ្រី សុខុម
៣៨- លោក ចាន់ ស៊ិន
៣៩- លោក រ៉ាត់ សោភា
៤០- លោក ខែន សារ៉ុម
៤១- លោក គង់ សោភ័ណ
៤២- លោក នូ សំអឿន
៤៣- លោក ធួន សេងកេង
៤៤- លោក មាស ណារិទ្ធ
៤៥- លោក ហួន គា
៤៦- លោក ជា សុផល
៤៧- លោក អ៊ាង វណ្ណថា
៤៨- លោក ចាប កុយ
៤៩- លោក ប៊ុល ខាំណារ៉េ
៥០- លោក ជួន ប៊ុនធឿន
៥១- លោក ហុង គីមជី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧ស.១០០៥.៤៤៣

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០

លេខៈ ៤០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះ

សពឯកឧត្តម ប៊ិន សំអូល

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០០៥.៤៤៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០

លេខៈ ៥១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោក **អាល់ប៊ែត្រូ ភាភារ៉ូ**

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

ចរ.ល. ១០០៥.៤៤៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០

លេខៈ ៣៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ស៊ុំ ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ :

១- លោកជំទាវ សៅ ពុទ្ធាទី
២-លោកអនុសេនីយ៍ឯក អ៊ុន អន
៣-លោកអនុសេនីយ៍ទោ ម៉ា រ៉ា
៤-លោកអនុសេនីយ៍ទោ ស៊ូ ចណ្ណា
៥-លោកអនុសេនីយ៍ទោ ឆោ ចណ្ណា
៦-លោកវេជ្ជបណ្ឌិត ធា សុខឡេង
៧-លោក ញ៉ឹក ម៉ុនលេខ
៨-លោកស្រី យូ សំា
៩-លោក គីត ចាន់ថា
១០-លោក សឿ សារៈខាន់
១១-លោកអនុសេនីយ៍ទោ ធី បញ៉ូ
១២-លោក សិទ្ធ ប៊ី
១៣-លោកអនុសេនីយ៍ទោ សាត លី
១៤-លោកអនុសេនីយ៍ទោ ម៉ុត នី
១៥-លោក លីម សុចណ្ណា
១៦-លោក អៀង ឡាដា
១៧-លោក គង់ លីដា
១៨-លោក អ៊ុន សុផាននរោរិទ្ធ

៣រ៧.១០០៥.៤៤៩

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១០

លេខ: ៤១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ៖

១- ឯកឧត្តម ទង់ វិស្សុត
២- ឯកឧត្តម តឹករ៉េត សំរេច
៣- លោក ចម ប៊ុរិទ្ធ
៤- លោក សេង សេដ្ឋា
៥- លោក ញឹម ទុង
៦- លោក ព្រុំ សេង
៧- លោក ទ៉ា សុណាថ

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ៖

១- លោក ជា សំណាត់
២- លោក ជា យុទ្ធឌីកា
៣- លោក ប៉ែន សុជាតិ
៤- លោក ស្រី ណារិទ្ធ
៥- លោក នង សុយ៉េត
៦- លោក ម៉ៅ ម៉ារិទ្ធ
៧- លោក ឈុន ហុង
៨- លោក ស៊ូ សៀង
៩- លោក ឡេង ម៉ៅ
១០- លោក សម ហេង
១១- លោក ថៃ ឬទ្ធី
១២- លោក វ័ន្ត សីលា
១៣- លោក ពិត ប្រាកដ
១៤- លោក ចេង វីរៈ
១៥- លោក ឃ្លោក យ៉ិត
១៦- លោក ប៉ាត សិត
១៧- លោក ឆី សាគុណ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ករល.១០០៥.៤៥០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១០

លេខ: ៥០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៥១០/៤៤៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានតែងតាំងសមាជិក នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម ៖

១- ឯកឧត្តម **កំសោន រដ្ឋលហ្វី** ជាសមាជិកអចិន្ត្រៃយ៍ មានឋានៈស្មើរដ្ឋលេខាធិការ
២- ឯកឧត្តម **ឌី សុខណាត** ជាសមាជិកអចិន្ត្រៃយ៍ មានឋានៈស្មើអនុរដ្ឋលេខាធិការ
៣- ឯកឧត្តម **អ៊ឹង វុទ្ធី** ជាសមាជិកមិនអចិន្ត្រៃយ៍បន្ថែមលើមុខងារបច្ចុប្បន្ន (ដោយមិនទទួលប្រាក់បៀវត្ស)។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា២.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៖ល. ១០០៥.៤៥១

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១០

លេខៈ ៥០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម លី គ្យុងស៊ូ

(H.E. LEE KYONG SOO)

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.១០០៥.៤៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១០

លេខៈ ៣៤៣ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជីនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៣ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក. ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្ដីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក. ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក , ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតំឡើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៨ អនក្រ.បក. ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣.១៣២ លានរៀល (បីពាន់មួយរយសាមសិបពីរលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាខាងក្រៅ) ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ចំណាយលើការចាក់ដីបំពេញទីធ្លាក្នុងបរិវេណវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតាកែវ ក្នុងឆ្នាំ ២០១០ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤១ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន០៦គ្រឿង ប្រគេននិងជូនសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង កុដិថ្មី ០២ជាន់ នៅវត្តកែវមណីរាម ស្ថិតក្នុងឃុំជ្រុងពពេល ស្រុករំដួល ខេត្តស្វាយរៀង ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

១-ព្រះតេជគុណ	កែវ ច័ន្ទ	ព្រះចៅអធិការវត្តកែវមណីរាម	បច្ច័យចំនួន	១៣.០០០ ដុល្លារ
២-ឧបាសិកា	អៀវ ជ័យណន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	១០.៦០០ ដុល្លារ
៣-លោក	ហៃ ហ៊ាង និង ភរិយា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	១០.៥០០ ដុល្លារ
៤-លោក	ជូ ជួន និង ភរិយា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	១០.១០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

-លោក	ពៅ សារួន និង ភរិយា	សប្បុរសជននៅខេត្តស្វាយរៀង	ថវិកាចំនួន	៥.៦០០ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ:

-លោក	ទ្រាំ ទ៉ាន់ នី និង ភរិយា	សប្បុរសជននៅខេត្តស្វាយរៀង	ថវិកាចំនួន	១.៣០០ ដុល្លារ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤៧ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៥រូប ដែលបានចូលរួមចំណែកក្នុងការបំរើប្រទេសជាតិ ការពារសន្តិសុខ សណ្តាប់ធ្នាប់ ស្ថិតនៅក្នុងឃុំពាមមន្ទារ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:

-លោកអនុសេនីយ៍ឯក **ឆេក ចន្ធូ** អត្តលេខ ៣៤១៣១ អនុប្រធាននគរបាលអន្តោប្រវេសន៍ច្រកបន្ទាយចក្រី

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:

១-លោកវរសេនីយ៍ត្រី **នុត គង់** អត្តលេខ ០៨៦៥៧ អនុប្រធានការិ.នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

២-លោកអនុសេនីយ៍ឯក **ស៊ីវ សុខុម** អត្តលេខ ០៤៤៧៣ អនុប្រធានការិ.នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៣-លោកអនុសេនីយ៍ឯក **នង សារិន** អត្តលេខ ០៨៦៦៣ នាយផ្នែក.នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៤-លោកអនុសេនីយ៍ឯក **ម៉ិត សុគុណ្ណា** អត្តលេខ ០៨៧២៨ ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តព្រៃវែង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៨រូប ដែលបានចូលរួមចំណែកក្នុងការកសាងអភិវឌ្ឍន៍ និងបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ កុដិ សាលាឆាន់ របងវត្ត ផ្លូវលំ និងសមិទ្ធផលនានាជាច្រើនទៀត នៅក្នុងវត្តមុនីសាគរ ស្ថិតនៅក្នុងឃុំពាមមន្ទារ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិៈ

១-ព្រះភិក្ខុ	ខាត់ សុគន	ចៅអធិការវត្តមុនីសាគរ ឃុំពាមមន្ទារ	បច្ច័យចំនួន ១៤.៥០០ ដុល្លារ
២-លោក	ណុំ សំបូរ	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៣.៥០០ ដុល្លារ
៣-លោក	ឡាយ ស៊ាប	មេឃុំពាមមន្ទារ ស្រុកកំពង់ត្របែក	ថវិកាចំនួន ១២.៥០០ ដុល្លារ
៤-លោក	នួច សីហា	ប្រធានការិ:សង្គមកិច្ច ស្រុកអូរជ្រៅ ខ.បន្ទាយមានជ័យ	ថវិកាចំនួន ១២.២០០ ដុល្លារ
៥-លោក	ចឹក ជឿច	ប្រធានអាចារ្យវត្តមុនីសាគរ	ថវិកាចំនួន ១១.៥០០ ដុល្លារ
៦-លោក	សៅ ឈុំ	សមាជិកគណៈកម្មការអាចារ្យវត្តមុនីសាគរ	ថវិកាចំនួន ១១.៣០០ ដុល្លារ
៧-លោក	ណុំ រ៉េន	សប្បុរសជននៅភូមិចំណោងទាក ឃុំពាមមន្ទារ	ថវិកាចំនួន ១១.០៥០ ដុល្លារ
៨-លោក	ខ៊ែត ទង់	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន ១១.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិៈ

១-លោក	នាង សាំ	សមាជិកគណៈកម្មការអាចារ្យវត្តមុនីសាគរ	ថវិកាចំនួន ៨.៧០០ ដុល្លារ
២-លោក	ខ៊ែត ពៅ	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន ៧.៨០០ ដុល្លារ
៣-លោក	សុក ឆាំ	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន ៧.៦០០ ដុល្លារ

៤-លោក	ឡូយ ហេងលី	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន	៧.៤០០ ដុល្លារ
៥-លោក	កែវ ជា	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន	៧.១០០ ដុល្លារ
៦-លោក	សៅ នាន	សប្បុរសជននៅភូមិក្រចាប់លើ ឃុំពាមមន្ទារ	ថវិកាចំនួន	៧.០៥០ ដុល្លារ

គ-មេដាយសិរីវឌ្ឍនស្ថាបនាជាតិ:

១-លោក	ស្វ នោម	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន	២.២០០ ដុល្លារ
២-លោក	សោម ឆោង	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន	២.១៥០ ដុល្លារ
៣-លោក	ស្វ អាង	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន	២.០៣០ ដុល្លារ
៤-លោក	ញ៉ឹម ស៊ាង	គណៈកម្មការវត្តមុនីសាគរ ឃុំពាមមន្ទារ	ថវិកាចំនួន	២.០៣០ ដុល្លារ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HR

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនមន្ត្រីនគរបាល ចំនួន០៣រូប ដែលបានលះបង់កម្លាំងកាយ-ចិត្ត ចូលរួមចំណែកជួយកសាងនិងអភិវឌ្ឍន៍សមិទ្ធផលនានាលើគ្រប់វិស័យ នៅវត្តព្រៃចំការ ស្ថិតនៅក្នុងឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

១-លោកអនុសេនីយ៍ឯក អ៊ិន សំអាត អត្តលេខ ១៣៧០១ អធិការរងនគរបាលស្រុកមេសាង

២-លោកអនុសេនីយ៍ទោ ទេ ទៀ អត្តលេខ ១១២០៣ នាយផ្នែកនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៣-លោកព្រិន្ទបាលឯក អ៊ូក សំណាង អត្តលេខ ៥០៤២៨ មន្ត្រីនគរបាលនៃអធិការដ្ឋាននគរបាលស្រុក

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារ កុដិ និងជួយឧបត្ថម្ភដល់ ប្រជាពលរដ្ឋក្រីក្រ នៅវត្តព្រៃចំការ ស្ថិតនៅក្នុងឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង ដូចមានរាយព្រះនាម និង នាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិៈ

-ព្រះតេជគុណ	ហ៊ន ហយ	ព្រះចៅអធិការវត្តព្រៃចំការ	បច្ច័យចំនួន ១០.០២៣ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិៈ

១-លោក	គីម ខាសនា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៥.៤២៨ ដុល្លារ
២-អ្នកស្រី	ម៉ម សារី	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៥.២៩៤ ដុល្លារ
៣-លោក	ជុំ អឿន	សប្បុរសជននៅខេត្តព្រៃវែង	ថវិកាចំនួន ៥.២៣៨ ដុល្លារ
៤-លោក	ចិន សំណាង	សប្បុរសជននៅខេត្តស្វាយរៀង	ថវិកាចំនួន ៥.១៨៣ ដុល្លារ
៥-លោក	កើន ឈុន	គណៈកម្មការវត្តព្រៃចំការ	ថវិកាចំនួន ៥.០៣៥ ដុល្លារ
៦-លោក	ស៊ុន អោម	អាចារ្យវត្តព្រៃចំការ	ថវិកាចំនួន ៥.០០០ ដុល្លារ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល ៖</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤៦ . អនក្រ . បក

អនុក្រឹត្យ

ស្តីពី

ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីលក្ខន្តិកៈដោយឡែក ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ
- តាមសំណើរបស់អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

សម្រេច

មាត្រា ១ : ត្រូវបានដាក់លោក **ឆុំ ឈេន** ប្រធាននាយកដ្ឋានសវនកម្មទី ២ នៃអាជ្ញាធរសវនកម្មជាតិ ឱ្យចូលនិវត្តន៍ក្នុងមុខតំណែង។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៨៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីរាជការខេត្តព្រះសីហនុ ចំនួន០៦រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម :-

១	វរសេនីយ៍ត្រី	**ហ៊ី ដួង**	០៤៣០៨ អធិការនគរបាល ស្រុកកំពង់សីលា
២	អនុសេនីយ៍ឯក	**សំ សាមាន**	០៣៦១២៤ មេបញ្ជាការកងរាជអាវុធហត្ថ ស្រុកកំពង់សីលា
